# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប២៥ឆ្នាំនៃព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច
# ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៧

អត្ថបទទី១៖ ១ពង្ស ៨,២២-២៣.២៧-៣០
អត្ថបទទី២៖ ១សិលា ២,៤-៩
ដំណឹងល្អ៖ មថ ១៦,១៣-១៩

បងប្អូនជាទីស្រឡាញ់!

សូមស្វាគមន៍ដល់បងប្អូនទាំងអស់ ដែលមកពីភូមិភាគភ្នំពេញ ភូមិភាគបាត់ដំបង និងកំពង់ចាម ស្វាគមន៍លោកឪពុកដែលមកយ៉ាងច្រើនថ្ងៃនេះ ដើម្បីអធិដ្ឋានរួមជាមួយគ្នា។ សូមថ្លែងអំណរគុណដល់លោកឪពុកផ័ត្រសិរី ដែលរៀបចំរួមជាមួយព្រះសហគមន៍សន្តយ៉ូសែប ពិធីប្រារព្ធ២៥ឆ្នាំនៃព្រះសហគមន៍នៅទីនេះ។ ពិតមែន ជាឱកាសមួយយ៉ាងល្អ ដើម្បីអរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យយើងមានកម្លាំងថ្មី ដើម្បីបន្តកសាងព្រះសហគមន៍របស់យើង។ ជាពិសេស យើងសូមស្វាគមន៍ និងអរគុណដល់លោកឪពុក វីរៈជ័យ ដល់លោកឪពុក ប៊ប់ ដែលបានជួយណែនាំព្រះសហគមន៍នេះបន្តពីលោកអេមីល និងក្រោយមកលោកប្រ៊ុយណូ និងសព្វថ្ងៃលោកផ័ត្រសិរី។

ថ្ងៃនេះ យើងមិនរំឭកដល់ថ្ងៃដែលយើងកសាងអាគារ គេហៅអនុទេវវិទ្យាល័យនៅក្នុងឆ្នាំ១៩១២។ ថ្ងៃនេះ យើងមិននឹករឭកដល់ពេលវេលាដែលកន្លែងនេះបានបិទទ្វារអស់ហើយនៅក្នុងសម័យប៉ុលពត និងបន្តពីសម័យប៉ុលពតក៏មិនអាចប្រើបានទេ។ ប៉ុន្តែថ្ងៃនេះ យើងមានអំណរសប្បាយ ដោយសារថ្ងៃនេះយើងគោរពថ្ងៃដែលយើងបានកសាងព្រះសហគមន៍សារជាថ្មី ថ្ងៃដែលព្រះសហគមន៍ដែលព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា បានរស់ឡើងវិញនៅក្នុង២៥ឆ្នាំកន្លងមក។ យើងនឹករឭកដល់ថ្ងៃដែលលោកអ៊ីវ និងលោកអេមីល នៅក្នុងឆ្នាំ១៩៨៩បានត្រឡប់មកវិញ យើងនឹកឃើញដល់ថ្ងៃបុណ្យចម្លង បុណ្យចូលឆ្នាំនៅឆ្នាំ១៩៩០ ដែលលោកអេម៉ីល បានថ្វាយអភិបូជាលើកដំបូងសារជាថ្មីនៅក្នុងសាលចេនឡា។ យើងបាននឹកឃើញនៅឆ្នាំ១៩៩២ នៅពេលយើងបានទទួលកន្លែងនេះសារជាថ្មី ដែលយើងបានទិញថែមដែរ និងលោកអ៊ីវ ជាមួយលោកអេមីល រួមជាមួយបងប្អូនគ្រីស្តបរិស័ទបានសម្អាត បានជួសជុល បានលាបថ្នាំ ដើម្បីឲ្យព្រះវិហារតូច ដើម្បីឲ្យទេវវិទ្យាយចាស់អាចប្រើបាន ឲ្យគ្រីស្តបរិស័ទអាចបន្តជួបជុំគ្នាជាមួយគ្នា៖ **ទីមួយ) ដើម្បីអធិដ្ឋាន ទីពីរ) ដើម្បីអប់រំជំនឿ និងទីបី) ដើម្បីចែករំលែកធម៌មេត្តាករុណាដល់អ្នកក្រីក្រ** យើងនឹករឭកដល់

ប៉ុន្មានឆ្នាំដែលយើងបានមានមហាសន្និបាតទូទាំងប្រទេសនៅទីនេះ ដោយប្រមូលទាំងគ្រីស្តបរិស័ទចាស់ ទាំងគ្រីស្តបរិស័ទថ្មី ដើម្បីគិតយើងចង់កសាងព្រះសហគមន៍របស់យើងសារជាថ្មីយ៉ាងដូចម្តេច? យើងចង់ធ្វើយ៉ាងម៉េចដើម្បីបន្តអប់រំជំនឿ? យើងត្រូវការរើសពាក្យខ្លះដើម្បីការអធិដ្ឋាន ប្រកាសដំណឹងល្អ ព្រះគម្ពីរដំណឹងល្អ អាចចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តបងប្អូនខ្មែរ។ យើងនឹកឃើញដល់មហាសន្និបាតរបស់យុវជន យុវនារី ទូទាំងប្រទេសដែលយើងធ្វើប៉ុន្មានដងនៅទីនេះ។ យើងនឹករឮកដល់ពេលវេលា ដែលកន្លែងនេះបានទៅជាក្រុងយេរ៉ូសាឡឹមយ៉ាងតូចនៅក្នុងប្រទេសកម្ពុជា ដោយសារទីកន្លែងដែលគ្រូអប់រំជំនឿបានចាប់ផ្តើមទៅដល់បាត់ដំបង ទៅកំពង់ចាម និងទៅដល់កន្លែងដាច់ស្រយាលនៃភូមិភាគភ្នំពេញ និងជាពិសេសនៅខេត្តកំពត និងខេត្តតាកែវ។ នៅសម័យនោះ លោកវីរៈជ័យ គាត់ទទួលភូមិភាគភ្នំពេញស្មើរទាំងមូលរហូតដល់កំពង់ឆ្នាំងទៀត។ ដូច្នេះ លោកឪពុកទទួលកំពត ទទួលតាកែវ ទទួលអ្វីច្រើនណាស់ដែលព្រះសហគមន៍លែងរាប់បាននៅសម័យនោះ។ យើងនឹកឃើញដល់ពេលវេលា ដែលយើងបានមានអំណរសប្បាយ ដើម្បីប្រកាសដំណឹងល្អសារជាថ្មី ដោយសារពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៨៩ និង១៩៩០ ដំណឹងល្អដែលយើងបានទទួលជាទ្រព្យសម្បត្តិ យើងទុកតែនៅក្នុងដួងចិត្តរបស់យើង ដោយសារយើងគ្មានសេរីភាពដើម្បីប្រកាសដំណឹងល្អ។

យើងនឹកឃើញដល់មណ្ឌលអ្នកជំងឺ ដែលលោកអភិបាលអេមីលបានបង្កើតសារជាថ្មី នៅក្នុងឆ្នាំ១៩៩២ភ្លាមៗ ដើម្បីទទួលបងប្អូនដែលឈឺមកពីខេត្តនានា ឲ្យគេបានមកព្យាបាលក្នុងមន្ទីរពេទ្យនៅភ្នំពេញ។ យើងនឹកឃើញដល់ក្រុមយុវជន ដែលជាមួយលោក វីរៈជ័យ បានបង្កើតសកម្មភាពយ៉ាងច្រើន។ យើងនឹកឃើញដល់ក្រុមចម្រៀង នៅថ្ងៃនេះលោកតា ម៉ម ប៊ុណ្ណារ៉ាយ មកមិនបានទេ តែនឹកឃើញដល់លោកតាដែលបានជួយជាមួយបងស្រីអាត តែលោកតាបាននិពន្ធបទចម្រៀងថ្មីៗយ៉ាងច្រើន ដើម្បីឲ្យជារៀងរាល់អាទិត្យយើងអាចច្រៀង និងអធិដ្ឋានអរព្រះគុណ និងកោតសរសើរព្រះជាម្ចាស់។

ដូច្នេះថ្ងៃនេះជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់មែនសម្រាប់អ្វីៗទាំងអស់ដែលកើតឡើងពីព្រះវិហារផ្សារតូចនេះនៅក្នុង២៥ឆ្នាំកន្លងមក ដែលណែនាំឲ្យព្រះសហគមន៍របស់យើងទូទាំងប្រទេសមានជីវិតសារជាថ្មី។

បងប្អូនជាទីស្រឡាញ់ ពិតមែនថ្ងៃនេះយើងនៅក្នុងអំណរសប្បាយរួមជាមួយសន្តយ៉ូសែប ជាស្វាមីរបស់ព្រះនាងម៉ារី។ ព្រះនាងម៉ារីដែលថ្ងៃនេះជាបុណ្យព្រះនាងម៉ារីនៃផ្កាំ ថ្ងៃនេះជាថ្ងៃមួយយ៉ាងពិសេស ដើម្បីនឹកឃើញនូវអ្វីៗទាំងអស់ដែលយើងបានទទួល និងដើម្បីអរព្រះគុណព្រះជាម្ចាស់។ ប៉ុន្តែ ប្រយ័ត្នកុំឲ្យយើងតែកោតសរសើរខ្លួនឯង កុំឲ្យយើងតែអរព្រះគុណព្រះជាម្ចាស់ កុំឲ្យយើងថាឥឡូវនេះយើងសប្បាយចិត្តហើយដែលយើងបានយកចិត្តទុកដាក់បង្កើតសកម្មភាពថ្មី បង្កើតព្រះសគមន៍ ដោយយើងមានអាគារយ៉ាងស្អាតដោយបានជួសជុលឆ្នាំកន្លងមក។ ផ្ទុយទៅវិញ ថ្ងៃនេះគឺជាថ្ងៃដែលយើងត្រូវតែមានកម្លាំងថ្មីដើម្បីនឹកឃើញដល់២៥ឆ្នាំខា ងមុខ មិនមែនតែនឹកឃើញដល់២៥ឆ្នាំកន្លងមក ប៉ុន្តែចាប់ពីពេលនេះទៅ ២៥ឆ្នាំខាងមុខនេះ តើយើងជាព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច ព្រះសហគមន៍នៅភូមិភាគភ្នំពេញ ធ្វើអ្វីខ្លះដើម្បីបន្តប្រកាសដំណឹងល្អ ដើម្បីបន្តធ្វើជាអ្នកដែលអធិដ្ឋាននៅក្នុងទីក្រុងភ្នំពេញ? ពិតមែន ស្ថានភាពនៅក្នុងព្រះសហគមន៍ភ្នំពេញរបស់យើងបានប្រែប្រួលហើយ យើងលែងមានព្រះសហគមន៍តែមួយដូចសម័យដើម សព្វថ្ងៃយើងមានមណ្ឌលសកម្មភាពប្រាំបួន។ សព្វថ្ងៃ យើងមានភ្នំពេញថ្មីដែលប្រមូលទាំងមហាសន្និបាត ទាំងការអប់រំ ទាំងសកម្មភាពយុវជនរួម។ សព្វថ្ងៃយើងអាចនិយាយថា ព្រះសហគមន៍របស់យើងជាព្រះសហគមន៍ដ៏មានជីវិត និងជាពេលវេលាមួយដើម្បីនឹកឃើញអត្ថបទទីពីរដែលយើងស្ដាប់អម្បាញ់មិញថា "**បងប្អូនប្រៀបបាននឹងថ្មដែលមានជីវិត**។ ២៥ឆ្នាំខា ងមុខនេះ តើយើងធ្វើយ៉ាងម៉េចដើម្បីឲ្យយើងបង្ហាញថា ពិតមែនយើងជាថ្មដែលមានជីវិតដើម្បីបន្តកសាងព្រះសហគមន៍របស់យើង និងជាពិសេសព្រះសហគមន៍សន្តយ៉ូសែបនៅផ្សារតូច ជាពិសេសមកដល់ភ្នំពេញខាងជើង ដើម្បីឲ្យព្រះសហគន៍របស់យើងជាព្រះសហគមន៍ដ៏មានជីវិត។

ដូច្នេះថ្ងៃនេះ ខ្ញុំអញ្ជើញបងប្អូនទាំងអស់ឲ្យសម្លឹងមើលព្រះនាងម៉ារី ព្រះនាងម៉ារីនៅក្នុងអាថ៌កំបាំងនៃព្រះនាងម៉ារី។ ថ្ងៃនេះយើងនឹកឃើញដល់អាថ៌កំបាំងទាំងបួន៖ **អាថ៌កំបាំងនៃអំណរសប្បាយអាថ៌កំបាំងនៃទុក្ខលំបាកអាថ៌កំបាំងនៃសិរីរុងរឿងនិងអាថ៌កំបាំងនៃពន្លឺ**។

**អាថ៌កំបាំងនៃអំណរសប្បាយ** ជាពេលវេលាមួយដែលព្រះនាងម៉ារីបានទទួលដំណឹងល្អធ្វើជាមាតារបស់ព្រះជាម្ចាស់ ជាពេលវេលាដែលព្រះនាងម៉ារីទៅសួរសុខទុក្ខយាយអេលីសាប៉ែត ជាពេលវេលាដែលព្រះនាងម៉ារីបានឲ្យព្រះយេស៊ូប្រសូត និងដើម្បីសង្គ្រោះមនុស្ស

យើងទាំងអស់។ អាថិកំបាំងនៃអំណរសប្បាយ ជាពេលវេលាដើម្បីឲ្យយើងរួមជាមួយព្រះនាងម៉ារី រួមជាមួយព្រះយេស៊ូ យើងចូលយ៉ាងជ្រៅនៅក្នុងជីវិតប្រចាំនៃទីក្រុងភ្នំពេញ។ នេះជាបេសកកម្មដែលយើងទទួល ដើម្បីទៅជាផ្លូងតែមួយ អង្គតែមួយដូចព្រះយេស៊ូនៅក្នុង ៣០ឆ្នាំនៅក្នុងភូមិណាសារ៉ែត ដើម្បីឲ្យយើងយកចិត្តទុកដាក់ជាមួយបងប្អូននៅក្នុងជុំវិញព្រះសហគមន៍របស់យើង ជាមួយអ្នកតូចតាច ជាមួយអ្នកដែលគ្មានទីពឹង ជាមួយកម្មករ ប្រសិនបើយើងដើរចេញនៅខាងក្រោយនោះ យើងឃើញមានរោងចក្រ និងមានភូមិកម្មករយ៉ាងច្រើន។ ជាមួយកូនក្មេង ជាមួយយុវជន យុវនារី ដែលកំពុងវង្វេងដោយសារគ្រឿងញៀន ជាមួយនិស្សិតនៅសាកលវិទ្យាល័យ ជាមួយយុវជន យុវនារី ដែលកំពុងស្វែងរក កំពុងឈ្វេងយល់ផ្លូវសម្រាប់ជីវិតរបស់ពួកគេ ដូចពេលព្រះនាងម៉ារី បានចូលជ្រៅនៅក្នុងទឹកដីនៃប្រទេសអ៊ីស្រាអែល។ ជាឱកាសមួយ សម្រាប់យើងដែលជាព្រះសហគមន៍នៅផ្សារតូច ដើម្បីចូលយ៉ាងជ្រៅថែមទៀតនៅក្នុងជីវិតនៃទីក្រុងភ្នំពេញ ដើម្បីទៅជាសាក្សីនៃអំណរសប្បាយដែលយើងទទួលពីព្រះយេស៊ូគ្រីស្ត។ ហេតុដូច្នេះហើយ ក្រុមយុវជនមណ្ឌលយ៉ូហានបាទីស្ត។ ជាពេលវេលាមួយសម្រាប់ក្រុមយុវជន សម្រាប់មណ្ឌលយ៉ូហានបាទីស្ត សម្រាប់សាលាមត្តេយ្យ សម្រាប់បណ្ណាល័យដែលព្រះសហគមន៍របស់យើងបានបង្កើតជាមួយកម្មករ ក្រុមលេស្យូម៉ារី ជាមួយក្រុមមេត្តាករុណា ដើម្បីយកចិត្តទុកដាក់ដោយភ្ជាប់ជាមួយបងប្អូនឯទៀតៗនៅក្នុងទីក្រុងភ្នំពេញ និងជាពិសេសនៅបរិវេណព្រះវិហារផ្សារតូច និងភ្នំពេញខាងជើងនេះ។ ជាពេលវេលាដើម្បីនៅទីនេះ យកពេលវេលានេះទៅជាសាក្សីនៃអំណរសប្បាយដូចព្រះនាងម៉ារីនៅទីនេះ នៅពេលនោះបានទៅជាសាក្សីនៃអំណរសប្បាយ។

**អាថិកំបាំងនៃទុក្ខលំបាក** នឹកឃើញព្រះនាងម៉ារីដែលនៅក្បែរឈើឆ្កាង។ ព្រះនាងម៉ារីកំពុងយំ ដោយសារកូនជាទីស្រឡាញ់របស់ព្រះនាងកំពុងស្លាប់ ព្រះនាងម៉ារីដែលកំពុងបីព្រះយេស៊ូដូចដែលយើងឃើញរូបនៅខាងឈើឆ្កាងនៅខាងមុខនេះ។ ព្រះនាងម៉ារី ដែលប្រមូលទុក្ខលំបាកនៃពិភពលោកទាំងមូល នៃមនុស្សលោកទាំងមូលរួមជាមួយព្រះយេស៊ូនៅលើឈើឆ្កាង។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទនៅទីនេះ ជាពេលវេលាដើម្បីប្រមូលទុក្ខលំបាក ទុក្ខព្រួយ បញ្ហាទាំងឡាយ ដែលបងប្អូនឯទៀតៗមានសព្វថ្ងៃ នៅក្នុងទីក្រុងភ្នំពេញ នៅក្នុងក្រុមគ្រួសារ ជាមួយអ្នកជំងឺផង ដើម្បីផ្ញើនូវទុក្ខលំបាកទាំងអស់ជាមួយព្រះ

យេស៊ូនៅលើឈើឆ្កាង តាមរយៈព្រះនាងម៉ារីនៅក្បែរឈើឆ្កាង។ ជាពេលវេលាមួយដើម្បីគិត យើងធ្វើយ៉ាងម៉េចដើម្បីបើកទ្វារយើងថែមទៀត? កន្លែងនេះមិនមែនជាកន្លែងឯកជន កន្លែងនេះជាកន្លែងសាធារណៈ ដើម្បីទទួលបងប្អូនឯទៀតៗឲ្យចេញចូលតាមសេរីភាព។ ដូច្នេះ យើងធ្វើយ៉ាងម៉េច ដើម្បីឲ្យកន្លែងនេះ ទៅជាកន្លែងមួយដើម្បីបើកដៃយ៉ាងទូលំទូលាយ បើកដួងចិត្តយ៉ាងទូលំទូលាយ ដើម្បីប្រមូល ដើម្បីស្វាគមន៍ ទុក្ខលំបាក ទុក្ខព្រួយ បញ្ហាទាំងឡាយរបស់បងប្អូនយើង និងជាពិសេសយើងមានមណ្ឌលសន្តលូកាសម្រាប់អ្នកជំងឺនៅទីនេះ ក្រុមធម៌មេត្តាករុណា ប៉ុន្តែកុំឲ្យយើងគិតតែក្រុមមេត្តាករុណា អាចធ្វើក្រុមសង្គហៈ អាចធ្វើជំនួសយើងបាន។ ឲ្យយើងយល់ថា យើងរៀងៗខ្លួនត្រូវតែធ្វើ ដើម្បីបង្ហាញមេត្តាករុណា តាមសមត្ថភាពយើង ប៉ុន្តែដោយអស់ពីសមត្ថភាពដោយមានចិត្តមេត្តា ដោយទទួលស្វាគមន៍ជានិច្ច ជាពិសេសទុក្ខលំបាករបស់បងប្អូនឯទៀតៗ។

**អាថ៌កំបាំងនៃសិរីរុងរឿង** ជាពេលវេលាដើម្បីមើលព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូដែលឡើងស្ថានបរមសុខ ព្រះយេស៊ូដែលផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះនាងម៉ារីដែលឡើងស្ថានបរមសុខរួមជាមួយព្រះជាម្ចាស់ និងទទួលសិរីរុងរឿងស្មើនឹងព្រះយេស៊ូដែរ នេះជាជំនឿរបស់យើង នេះជាសេចក្តីសង្ឃឹមរបស់យើង។ យើងបានស្តាប់នៅក្នុងអត្ថបទទីមួយអម្បាញ់មិញថា "**ទីនេះជាកន្លែងសម្រាប់នាមយើង** ទីនេះនៅផ្សារតូច ដើម្បីកោតសរសើរព្រះនាមរបស់ព្រះជាម្ចាស់ ជាពេលវេលាមួយដើម្បីបង្ហាញអំពីអំណរសប្បាយរបស់យើង សេចក្តីសង្ឃឹមរបស់យើង ជាពិសេសតាមរយៈការអធិដ្ឋាន តាមរយៈកោតសរសើរព្រះជាម្ចាស់។ សម្រាប់ក្រុមពិធីបុណ្យ សម្រាប់ក្រុមចម្រៀង អភិបូជានានា ពិធីបុណ្យឱឡារឹកនានា ជាឱកាសមួយដើម្បីច្រៀងកោតសរសើរព្រះជាម្ចាស់ ឲ្យសំឡេងរបស់យើងចេញពីព្រះវិហារផ្សារតូចនេះ និងហៀរនៅក្នុងទីក្រុងភ្នំពេញទាំងមូលរហូតដល់ស្ថានបរមសុខ ដើម្បីបង្ហាញថាពិតមែនយើងពោរពេញដោយសេចក្តីសង្ឃឹមនៅក្នុងសិរីរុងរឿងរបស់ព្រះជាម្ចាស់ នៅពេលយើងកោតសរសើរព្រះអង្គ នៅពេលអធិដ្ឋានដោយស្ងៀមស្ងាត់ នៅពេលតាំងព្រះកាយព្រះគ្រីស្ត ដោយយើងច្រៀងអស់ពីដួងចិត្ត។ នេះជាសេចក្តីសង្ឃឹមរបស់យើង និងសេចក្តីសង្ឃឹមណែនាំឲ្យយើងមានជីវិត។

**អាថ៌កំបាំងនៃពន្លឺ** ដែលសន្តយ៉ូហានប៉ូលទីពីរ បានបន្ថែមឲ្យព្រះសហគមន៍អធិដ្ឋានយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ និងព្រះនាងម៉ារីថែមទៀត។ នេះជាជីវិតនៃព្រះសហគមន៍!

អាចិកំបាំងនៃពន្លឺជាជីវិតនៃព្រះសហគមន៍ ពិធីជ្រមុជទឹក មង្គលការ ពិធីកាច់នំប៉័ង ការប្រកាសដំណឹងល្អ និងព្រះរាជ្យព្រះជាម្ចាស់ ព្រះយេស៊ូដែលសម្តែងព្រះពន្លឺ សម្តែងឋានៈជាព្រះអង្គ ជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះសហគមន៍ផ្សារតូចជាកន្លែងមួយ ដើម្បីទទួលបងប្អូន ដើម្បីណែនាំបងប្អូនជាពិសេសឲ្យកូនៗរបស់បងប្អូនទទួលពិធីជ្រមុជទឹក និងទទួលជីវិតរួមជាមួយព្រះយេស៊ូ។ ជាពេលវេលា ដើម្បីឲ្យបងប្អូនបង្កើតគ្រួសារថ្មីនៅក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍ ជាពេលវេលាដើម្បីអធិដ្ឋាន និងកាច់នំប៉័ងប្រចាំថ្ងៃ ជាពេលវេលាដើម្បីធ្វើដំណើរចុងក្រោយនៅពេលយើងធ្វើមរណភាព។ ប៉ុន្តែជាពេលវេលាមួយដែរ ដើម្បីប្រកាសដំណឹងល្អ មិនមែនថែរក្សាជីវិតរបស់យើងខាងវិញ្ញាណរបស់យើងតែប៉ុណ្ណឹង ដើម្បីឲ្យយើងប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយអញ្ជើញបងប្អូនឯទៀតៗ ឲ្យគេស្គាល់ព្រះយេស៊ូគ្រីស្ត។ នេះជាឱកាសមួយសម្រាប់ក្រុមលោកគ្រូអប់រំជំនឿ ដើម្បីភ្ញាក់ស្មារតី ដោយបន្តការអប់រំ ដើម្បីអប់រំជំនឿរបស់យើងតៗ ដើម្បីណែនាំឲ្យជីវិតដែលមកពីព្រះយេស៊ូអាចយាងចូលនៅកន្លែងយ៉ាងច្រើន។

យើងសប្បាយចិត្ត ដោយសារយើងមានព្រះសហគមន៍ថ្មី ជាពិសេសនៅព្រៃកតាទែន។ ប៉ុន្តែខ្ញុំជឿថា នៅក្នុងបរិវេណរបស់ផ្សារតូច និងមណ្ឌលខាងជើងយើងមានកន្លែងយ៉ាងច្រើន ដើម្បីឲ្យយើងប្រកាសដំណឹងល្អថែមទៀត និងដើម្បីឲ្យយើងទៅជួបជាមួយបងប្អូនដែលកំពុងស្រេកឃ្លាន ដែលកំពុងទន្ទឹងរង់ចាំសេចក្តីសង្ឃឹមមួយ និងជូនកាលគេមិនដឹងទេសេចក្តីសង្ឃឹមរបៀបណា? ប៉ុន្តែនេះជាតួនាទីរបស់យើងជាគ្រីស្តទូតដែលព្រះយេស៊ូបានតែងតាំងយើងដើម្បីប្រកាសដំណឹងល្អថែមទៀត និងសារជាថ្មីទៀត។ ដូច្នេះគ្រូអប់រំជាមួយបូជាចារ្យដែលទទួលខុសត្រូវនៅទីនេះ រួមជាមួយបងស្រី បងប្រុស រួមជាមួយបងប្អូនដែលផ្តល់សាក្ខីភាពផ្ទាល់ខ្លួន យើងដឹងថាពិតមែនយើងទទួលតួនាទីមួយ ដើម្បីឲ្យជីវិតប្រចាំថ្ងៃរបស់យើងទទួលសិរីរុងរឿង ទទួលភាពដ៏វិសុទ្ធតាមអគ្គសញ្ញានីមួយៗ។ ប៉ុន្តែយើងធ្វើយ៉ាងម៉េចដើម្បីទៅប្រកាសដំណឹងល្អថែមទៀត នៅពេលនោះគេថាព្រះបន្ទូលរបស់ព្រះយេស៊ូសម្រាប់លោក សិលា ទៅជាព្រះបន្ទូលសម្រាប់យើង។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំសូមប្រាប់អ្នកថា អ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ**" ថ្ងៃនេះជាព្រះបន្ទូលសម្រាប់យើង។ មិនមែនគ្រាន់តែជាព្រះបន្ទូលសម្រាប់លោកសិលា ២០០០ឆ្នាំមុន មិនមែនជាព្រះបន្ទូលសម្រាប់តែសម្តេចប៉ាបដែលបន្ត

តួនាទីពីលោកសិលា២០០០ឆ្នាំកន្លងមក។ ប៉ុន្តែនេះជាព្រះបន្ទូលសម្រាប់ខ្ញុំផ្ទាល់ សម្រាប់យើងរៀងៗខ្លួនផ្ទាល់។ យើងជាសិលា យើងនឹងសាងសង់ព្រះសហគមន៍នៅលើផ្ទាំងសិលានេះ មានន័យថាព្រះយេស៊ូទន្ទឹងរង់ចាំ សង្ឃឹមលើយើង ដើម្បីកសាងព្រះសហគមន៍របស់ព្រះគ្រីស្ត។

ដូច្នេះឲ្យយើងមានកម្លាំងកាយ កម្លាំងចិត្ត ឲ្យយើងមានជំនឿរឹងមាំ ឲ្យយើងឈរឡើង។ **គ្រីស្តបរិស័ទអើយ! ដើម្បីប្រកាស ពិតមែនយើងជាថ្មដែលមានជីវិតនិងរួមគ្នា យើងចង់កសាងព្រះសហគមន៍របស់ព្រះគ្រីស្ត ដោយសារព្រះគ្រីស្តបានជ្រើសរើសយើង ដូចព្រះយេស៊ូបានជ្រើសរើសលោកសិលានិងក្រុមគ្រីស្តទូតពីដើម ។**

នៅពេលនេះ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់២៥ឆ្នាំកន្លងមក យើងទូលអង្វរព្រះជាម្ចាស់សម្រាប់២៥ឆ្នាំខាងមុខនេះ ដោយដឹងថា៥០ឆ្នាំគ្រប់គ្រាន់ ដើម្បីធ្វើឆ្នាំព្រះមហាករុណាទិគុណ ដោយទូលអង្វរព្រះនាងម៉ារីនៃទន្លេមេគង្គនៅអរិយ៍ក្សត្រ ដែលជួយមើលយើង ថែរក្សាយើងជានិច្ច នេះជាសេចក្តីសង្ឃឹមចំពោះយើង។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយទូលអង្វរព្រះអង្គធ្វើយ៉ាងម៉េច ដើម្បីឲ្យយើងបន្តកសាងព្រះសហគមន៍យ៉ាងស្អាត ដូចបងប្អូនបានសាងសង់អស់រយៈពេល២៥ឆ្នាំកន្លងមក។

**ជ័យោព្រះសហគមន៍! ជ័យោព្រះជាម្ចាស់! អាម៉ែន! អាលេលូយ៉ា!!!**